# ***ឯកសារសង្ខេប***

*រៀបចំជូនគណៈកម្មការទី២ ព្រឹទ្ធសភាទទួលបន្ទុកសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម*

***ស្តីពី***

## ការអនុវត្ត និងត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិ
## ក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ


រៀបចំដោយៈ លោកស្រី អ៊ុង ណារី

ជំនួយការដោយៈ លោកស្រី តុប ដារី


*រាជធានីភ្នំពេញថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០១៨*

**វិទ្យាស្ថានសភាកម្ពុជា**

# មាតិកា

**សាវតានៃក្របខណ្ឌច្បាប់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការថ្នាក់ក្រោមជាតិ** ........ 1

I. **ការអភិវឌ្ឍនៃក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ** ........ 1

១. ការអភិវឌ្ឍច្បាប់ ........ 1

១.១ រដ្ឋធម្មនុញ្ញកម្ពុជា (វិសោធនកម្មឆ្នាំ ២០១០) ........ 2

១.២ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត ក្រុង (១៩៩៨) ........ 2

១.៣ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១) ........ 2

១.៤ ច្បាប់រៀបចំអង្គការស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ(២០០៨) ........ 3

២. ក្របខ័ណ្ឌគោលនយោបាយ ........ 3

II. **ប្រព័ន្ធហិរញ្ញវត្ថុ** ........ 4

III. **ដៃគូអភិវឌ្ឍ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ** ........ 6

IV. **សេចក្តីសន្និដ្ឋាន** ........ 8

**ឯកសារយោង** ........ 9

**ឧបសម្ព័ន្ធ** ........ 11

# ការអនុវត្ត និងត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិ ក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ

ឯកសារសង្ខេបនេះផ្តល់ព័ ត៌មានគន្លឹះជូនគណៈកម្មការទី២ ទាក់ទងនឹង បេសកកម្មស្វែងរកព័ត៌មានចាប់ពីថ្ងៃទី ១១ -១៤ មីនា ២០១៤ លើប្រធានបទស្តីពី "**ការអនុវត្ត និងត្រួតពិនិត្យថវិកាថ្នាក់ក្រោមជាតិក្នុងបរិបទវិមជ្ឈការ និងវិសហមជ្ឈការ** " នៅខេត្តឧត្តរមានជ័យ និងខេត្តសៀមរាប។

## សាវតានៃក្របខណ្ឌច្បាប់ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការថ្នាក់ក្រោមជាតិ

កម្មវិធីវិមជ្ឈការនៅកម្ពុជា គឺជា សមិទ្ធផលអស់រយៈពេលជាច្រើនទសវត្សន៍ នៃកំណែទម្រង់ច្បាប់ និងគោលនយោបាយ ដែលចាប់ផ្តើមដំបូងតាមរយភម្មវិធីសីលា (SEILA)[1] ឆ្នាំ ១៩៩៦។ បន្ទាប់ពីមានសង្គ្រាម និង ចលាចលសង្គមអស់ជាច្រើនឆ្នាំ គោលបំណងដំបូង របស់កម្មវិធីសាកល្បងនេះគឺ ការរៀបចំមូលដ្ឋានដើម្បី ផ្សះផ្សារជាតិ និងការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម ។ ទោះជាយ៉ាងណាក៏ដោយ ប្រពន្ធ័នៃការគ្រប់គ្រងហិរញ្ញវត្ថុ និងការអភិវឌ្ឍជនបទត្រូវបានបង្កើតឡើងក្នុងខេត្តចំនួនប្រាំ ដែលត្រូវបានពង្រីកទៅគ្រប់ម្ភៃបួនខេត្ត ក្រុងក្នុង ឆ្នាំ ២០០៣ ក្នុងដំណាក់កាលលើកកម្ពស់អភិបាលកិច្ចមូលដ្ឋាន និងការធ្វើផែនការចូលរួម ។

## I. ការអភិវឌ្ឍនៃក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ

### ១. ការអភិវឌ្ឍច្បាប់

ផ្នែកខាងក្រោមនេះនឹងផ្តល់នូវទិដ្ឋភាពសង្ខេបពីក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ដែលទាក់ទងនឹងការអនុវត្ត និងអភិវឌ្ឍនៃកំណាទម្រង់គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ។

[1] ធនាគារពិភពលោក, កម្មវិធីសីឡារបស់ប្រទេសកម្ពុជា: វិធីសាស្រ្តវិមជ្ឈការដើម្បីអភិវឌ្ឍជនបទ និងកាត់បន្ថយភាពក្រីក្រ (កម្ពុជា: ធនាគារពិភពលោក,២០០៤),ទ.១.

### ១.១ រដ្ឋធម្មនុញ្ញកម្ពុជា (វិសោធនកម្មឆ្នាំ ២០១០)

មាត្រា ៣ បានចែងថា ព្រះរាជាណាចក្រ កម្ពុជាជារដ្ឋដែលមិនអាចបំបែកបាន។ រដ្ឋធម្មនុញ្ញ មិនបានសំដៅលើវិមជ្ឈការ និងវិសហមជ្ឈការទេ ប៉ុន្តែមាត្រា ១៤៥ បានលើកឡើងថា ទឹកដីនៃព្រះរាជាណាចក្រចែកជារាជធានី, ខេត្ត, ក្រុង, ស្រុក, ខណ្ឌ, ឃុំ សង្កាត់។

- មាត្រា ៥១ ចែងពីការបែងចែកអំណាច ដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ, នីតិប្រតិបត្តិ និងអំណាចតុលាការ។
- មាត្រា ១៤៦ ចែងថា រាជធានី ខេត្ត, ក្រុង, ស្រុក , ខ័ណ្ឌ , ឃុំ សង្កាត់ ត្រូវគ្រប់គ្រងតាមលក្ខខណ្ឌ ដែលមានចែងក្នុងច្បាប់រៀបចំអង្គការ។

### ១.២ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិខេត្ត ក្រុង (១៩៩៨)

ច្បាប់នេះបានបង្ហាញពីមូលដ្ឋានសម្រាប់ការរៀបចំធ្វើសេចក្តីព្រាងច្បាប់គ្រប់គ្រងហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែល បច្ចុប្បន្នកំពុងព្រាង។ បច្ចុប្បន្ន ច្បាប់នេះត្រូវបានប្រើប្រាស់ និងអនុញ្ញាតអោយអភិបាល និងអភិបាលរងខេត្ត ក្រុងធ្វើការ គ្រប់គ្រងថវិកា និងទ្រព្យសម្បត្តិតាងនាមអោយរដ្ឋាភិបាលកណ្តាល[2]។

### ១.៣ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ (២០០១)

ច្បាប់នេះបានបង្កើតការគ្រប់គ្រងរដ្ឋបាលគ្រប់ឃុំ/សង្កាត់ទាំងអស់នៅព្រះរាជាណាចក្រកម្ពុជាស្របតាមគោលនយោបាយវិមជ្ឈការ។ ច្បាប់នេះចែងថា ឃុំនីមួយៗ ត្រូវមានក្រុមប្រឹក្សាមួយដែលហៅថាក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សានីមួយៗមានអំណាចក្នុងការគ្រប់គ្រងកិច្ចការមូលដ្ឋាននៅក្នុងឃុំរបស់ខ្លួន។ គួរកត់សម្គាល់ថា មាត្រា៤នៃច្បាប់នេះបានចែងថា អំណាចគ្រប់គ្រង និងដឹកនាំរបស់ឃុំ ការគ្រប់គ្រងរបស់ឃុំ(ឃុំសង្កាត់)គឺ ទទួលបានពីការបោះឆ្នោតដោយផ្ទាល់។ ជាងនេះទៅទៀត មាត្រា១១ បានចែងថា ក្រុមប្រឹក្សាឃុំ គឺត្រូវបោះឆ្នោតជ្រើសរើសដោយផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងឃុំរបស់ខ្លួនសម្រាប់អាណត្តិរយៈពេល០៥ ឆ្នាំ ។

---

[2] Tariq H. Niazi, Deconcentration and Decentralization in Cambodia (ហ្វីលីពីន:ធនាគារអភិវឌ្ឍអាស៊ី,២០១១), ទ.១០១.

## ១.៤ ច្បាប់រៀបចំអង្គការស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុកខណ្ឌ(២០០៨)

ច្បាប់នេះមានសារៈសំខាន់ណាស់ក្នុងក្របខ័ណ្ឌវិមជ្ឈការ និងវិសហមជ្ឈការ : មាត្រា៨ បានបញ្ជាក់ពីរាជធានី ខេត្ត ក្រុង ស្រុ ក ខណ្ឌ ជានីតិបុគ្គលសាធារណៈគ្រប់គ្រងតាមគោលការណ៍រដ្ឋបាលឯកភាព។ រដ្ឋបាលថ្នាក់ក្រោមជាតិកម្រិតនីមួយៗត្រូវអនុវត្ត លើកកម្ពស់ និងទ្រទ្រង់ការអភិវឌ្ឍបែបប្រជាធិបតេយ្យ តាមរយៈគោលនយោបាយវិមជ្ឈការ និងវិ សហមជ្ឈការ។ ប៉ុន្តែផ្ទុយពីថ្នាក់ឃុំ ក្នុងមាត្រា ១៤ នៃច្បាប់រៀបចំអង្គការបានលើកឡើងថា ក្រុម ប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុ ក ខណ្ឌ គឺ បោះឆ្នោតជ្រើសរើសអសកល តាមនីតិវិធីនៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី, ក្រុមប្រឹក្សាខេត្ត, ក្រុមប្រឹក្សាក្រុង, ក្រុមប្រឹក្សាស្រុក, ក្រុមប្រឹក្សាខណ្ឌ។

## ២. ក្របខ័ណ្ឌគោលនយោបាយ

ចេញពីទស្សនៈគោលនយោបាយជាតិ រាជរដ្ឋាភិបាលកម្ពុជា( RGC)បានចាប់ផ្តើមផ្សព្វផ្សាយកម្មវិធីដំណើរការក្របខណ្ឌ័យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ (យុទ្ធសាស្ត្រ D&D) ក្នុងឆ្នាំ ២០០៥ ក្នុងគោលដៅចម្បងគឺ ដើម្បីលើកកម្ពស់ការផ្តល់សេវាសាធារណៈ បន្តការ ធ្វើវិមជ្ឈការសារពើពន្ធ និងបង្កើតក្របខ័ណ្ឌច្បាប់ដើម្បីបង្កើនប្រភពចំណូលរបស់ខ្លួននៅកម្រិតថ្នាក់ឃុំ ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រឆ្នាំ ២០០៥ នេះគឺជាឯកសារគោលដែលនាំឲ្យមានច្បាប់រៀបចំអង្គការឆ្នាំ២០០៨។

បន្ថែមពីលើក្របខ័ណ្ឌច្បាប់ និងដើម្បី លើកកម្ពស់យុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ឆ្នាំ ២០០៥ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍ បែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NP-SNDD) ត្រូវបានបង្កើតឡើង និង បានអនុម័តជាផ្លូវការដោយទីស្តីការគណៈរដ្ឋមន្ត្រីក្នុងឆ្នាំ ២០១០ ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NP-SNDD) បានដាក់ចេញនូវរបៀបវារៈរយៈពេល ១០ឆ្នាំរបស់រាជរដ្ឋាភិបាល ដើម្បីអនុវត្តយុទ្ធសាស្ត្រវិមជ្ឈការ និងវិសហមជ្ឈការ ។

កម្មវិធីចម្បងចំនួន០៥ត្រូវបានកំណត់ដូចខាងក្រោម:

១. ការអភិវឌ្ឍស្ថាប័នថ្នាក់ក្រោមជាតិ
២. ការអភិវឌ្ឍភាពរឹងមាំនៃប្រពន្ធ័គ្រប់គ្រងធនធានមនុស្ស
៣. ការផ្ទេរមុខងារ និងធនធាន

៤. ថវិកាថ្នាក់ក្រោមជាតិ, ប្រពន្ធ័គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ
៥. ការគាំទ្រស្ថាប័នសម្រាប់ដំណើរការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

ប៉ុន្តែគោលនយោបាយទាំងនេះ នៅមិនទាន់បានបញ្ជាក់ច្បាស់ពី តួនាទី សមត្ថកិច្ច និងមុខងាររបស់រដ្ឋបាលកម្រិតនីមួយៗទេ។ ទន្ទឹមនឹងនេះផងដែរក្នុងឆ្នាំ ២០១០ គណៈកម្មការជាតិសម្រាប់អភិវឌ្ឍន៍តាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(NCDD)[3] ក៏បានបង្កើតផែនការប្រតិបត្តិរយៈពេល៣ឆ្នាំដំបូង (IP3, 2011) ផងដែរ ។ នេះគឺជាគណៈកម្មការអន្តរក្រសួង ដែលបានបង្កើតឡើងដើម្បីគាំទ្រការងាររបស់ក្រសួងក្នុងកម្រិតបច្ចេកទេសនិ ងជួយសម្របសម្រួលក្នុងការអនុវត្តនូវកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (NP-SNDD) លើកដំបូង។ ប៉ុន្តែនេះជាកម្មវិធីមួយដែលមានភាពស្មុគស្មាញ ហើយមានមហិច្ឆតាខ្ពស់ក្នុងការអនុវត្ត រួមទាំងជាមួយគ្រប់ ដៃគូពាក់ព័ន្ធទាំងអស់។ ឯការ សម្របសម្រួល/សហការរវាងក្រសួងនីមួយៗក៏នៅមានបញ្ហាប្រឈមច្រើនដែរ។ ដូច្នេះសកម្មភាពជាច្រើនត្រូវបានអូសបន្លាយក្នុងការអនុវត្តជាច្រើនឆ្នាំ ។

## II. ប្រព័ន្ធហិរញ្ញវត្ថុ

ផ្នែកខាងក្រោមពន្យល់ជាសង្ខេបពីច្បាប់ដែលពាក់ពន្ធ័នឹងប្រពន្ធ័ហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជារួមទាំងច្បាប់រៀបចំអង្គការ(២០០៨) ច្បាប់ស្តីពី ប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ (២០០៨) និងសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលថ្នាក់ក្រោមជាតិ(កែសម្រួលចុងក្រោយឆ្នាំ ២០០៨)។

គួរកត់សម្គាល់ថា មានភាពខុសគ្នាមួយចំនួន រវាងច្បាប់រៀបចំអង្គការ និងច្បាប់ស្តីពី ការគ្រប់គ្រងប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈដូចខាងក្រោម:

ច្បាប់រៀបចំអង្គការផ្តល់ស្វ័យភាពច្រើនដល់ក្រុមប្រឹក្សាដែលជាប់ឆ្នោតក្នុងការគ្រប់គ្រងថវិកាចំណូលសារពើពន្ធមូលដ្ឋាន និងចំណូលមិនមែនសារពើពន្ធដូចដែលរៀបរាប់ ក្នុងមាត្រា ២៤៤ ខាងក្រោម:

- " *ក្រុមប្រឹក្សារាជធានី, ក្រុមប្រឹក្សាខេត្ត, ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សា ស្រុកមានសិទ្ធិទទួលចំណូលពីមូលដ្ឋាន, ជាតិ និងប្រភពចំណូលផ្សេងទៀត អនុលោមតាមច្បាប់ ស្តីពី*

[3] ទាញយកពី http://www.ncdd.gov.kh/en/about-ncdd

*របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលត្រូវបាន បង្កើតស្របទៅនឹងច្បាប់នេះ និងច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ ”។*

- *“ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាសង្កាត់មានថវិកាសម្រាប់អនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ដែលនឹងត្រូវបញ្ចូលក្នុងថវិការបស់ក្រុមប្រឹក្សារាជធានី និងក្រុង”*

ម្យ៉ាងវិញទៀត ច្បាប់ស្តីពី ប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ ច្រើនផ្តល់នូវវិធីសាស្ត្រមជ្ឈការក្នុងការគ្រប់គ្រង និងត្រួតពិនិត្យថវិកា។

-មាត្រា ៣៤និងមាត្រា ៣៥ ចែងថា អភិបាលត្រូវរៀបចំគម្រោងយុទ្ធសាស្រ្តថវិកា និងថវិកាសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNAs) តាមប្រតិទិន និងគោលការណ៍ណែនាំ ដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (MEF) និងអោយស្របតាមសារាចរណែនាំរបស់ក្រសួងដែលដាក់ចេញ។ ផ្តោតសំខាន់ជាងនេះទៅទៀត មាត្រា ៣៥ បានចែងថា:

- មាត្រា ៣៥(១) ផែនការយុទ្ធសាស្រ្តថវិកាត្រូវរៀបចំពីខែមីនា ដល់ខែឧសភាជារៀងរាល់ឆ្នាំ

- មាត្រា៣៥(២) កញ្ចប់ថវិកាត្រូវរៀបចំពីខែមិថុនា ដល់ខែកញ្ញាជារៀងរាល់ឆ្នាំ

- មាត្រា ៣៥(៣) ថវិកានៅរដ្ឋបាលថ្នាក់ក្រោមជាតិ( SNAs) ត្រូវអនុម័តចាប់ពីខែតុលា ដល់ខែធ្នូជារៀងរាល់ឆ្នាំ

ជាងនេះទៅទៀតក្នុងសប្តាហ៍ទី១ នៃខែតុលាជារៀងរាល់ឆ្នាំ ក្រសួងសេដ្ឋកិច្ច នឹងហិរញ្ញវត្ថុ (MEF) នឹងផ្ញើគម្រោងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ( SNAs) ទៅកាន់ទីស្តីការគណៈរដ្ឋមន្រ្តីដើម្បីពិនិត្យ និងអនុម័ត។ នៅក្នុងផែនការថវិកាមានជំពូកមួយស្តីពី សេចក្តីព្រាងច្បាប់ថវិកាជាតិប្រចាំឆ្នាំ ។ បន្ទាប់មកសេចក្តីព្រាងច្បាប់នេះត្រូវដាក់ជូន រដ្ឋសភាដើម្បីអនុម័តក្នុងសប្តាហ៍ទីមួយនៃខែវិច្ឆិកា រួចដាក់ជូនព្រឹទ្ធសភាដើម្បីអនុម័តចុងក្រោយក្នុងសប្តាហ៍ដំបូងនៃខែធ្នូ។ ការអនុម័តផែនការថវិកាចុងក្រោយត្រូវធ្វើត្រឹមថ្ងៃទី២៥ ខែធ្នូ នៃឆ្នាំនីមួយៗ។

សង្ឃឹមថា ភាពមិនស្របគ្នារវាងច្បាប់រៀបចំអង្គការ និងច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ នឹងត្រូវដោះស្រាយ បន្ទាប់ពីច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិ (SNA) ដែលបច្ចុប្បន្ន កំពុងព្រាង (កែសម្រួលលចុងក្រោយឆ្នាំ២០០៨) ត្រូវ បានអនុម័ត។ ច្បាប់នេះនៅពេលអនុម័តរួច វានឹងជួយ កំណត់បន្ថែមពីការទទួលខុសត្រូវ និង ការ គ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ របស់រដ្ឋបាលថ្នាក់ក្រោមជាតិថវិកា និងការគ្រប់

គ្រងថវិកា ការទទួលខុសត្រូវ ការរៀបចំការអនុម័ត និងការប្រតិបត្តិថវិកានៅថ្នាក់ក្រោមជាតិ ក៏ដូច ជាការគ្រប់គ្រងទ្រព្យសម្បត្តិនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទាក់ទងទៅនឹងសេចក្តីព្រាងច្បាប់ស្តីពី របបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ:

- មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់នេះបានចែងថា រតនាគាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើរតួជាគណនេយ្យសាធារណៈសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ហើយត្រូវទទួលខុសត្រូវចំពោះការងារដូចខាងក្រោម:
    - ការប្រមូល ឬ ទទួលចំណូលសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ;
    - ប្រតិបត្តិការអាណត្តិបើកប្រាក់ដែលចេញដោយអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
    - ការគ្រប់គ្រង និងផ្តល់មូលនិធិសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ
    - ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឲ្យបានទៀងទាត់
    - ការរៀបចំ និង រក្សារាល់ឯកសារទាំងអស់ ដែលទ្រទ្រង់អន្តរកម្មចំណូល ចំណាយ និងការកំណត់ត្រាគណនេយ្យរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។
- មាត្រា ១៦ នៃសេចក្តីព្រាងច្បាប់នេះចែងថា ប្រធាននាយកដ្ឋានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ , ប្រធានរតនាគារ, ប្រធានសាខាពន្ធដារ ឬ ការិយាល័យពន្ធដារ ដែលស្ថិតក្នុងសមត្ថកិច្ចនៃរដ្ឋបាលថ្នាក់ក្រោមជាតិ នឹងទទួលបានប្រតិភូកម្មអំណាចពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ និងគណៈអភិបាលក្នុងការអនុវត្តច្បាប់នេះ។

## III. ដៃគូអភិវឌ្ឍ និងកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

នៅពេលដែលមានដៃគូអភិវឌ្ឍន៍ជាច្រើនចូលរួមគាំទ្រការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ (D&D) ក្នុងប៉ុន្មានទសវត្សរ៍កន្លងមកនេះ ផ្នែកនេះនឹងផ្តោតលើធនាគារអភិវឌ្ឍន៍អាស៊ី(ADB) ដែលជាដៃគូគាំទ្រដ៏ចម្បងទាំងផ្នែកថវិកា និងបច្ចេកទេសទៅលើការងារកែ ទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ(D&D) ចាប់តាំងពីឆ្នាំ២០០៣ មកម្ល៉េះ។ ជាក់ស្តែងយោងតាមរបាយការណ៍ឆ្នាំ ២០១១ ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) បានរួមចំណែកជាថវិកាលើការងារកែទម្រង់នេះចំនួនប្រមាណ ៨៥.៤ លានដុល្លារអាមេរិក ដែល ក្នុងនោះ ៦៨ លានដុល្លារ អាមេរិកជាជំនួយ

ឥតសំណងសម្រាប់គម្រោងជួយក្នុងការអភិវឌ្ឍ[4] ។ នៅពេលនោះមានគម្រោងមួយឈ្មោះ "ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ:សម្រាប់កម្មវិធីអភិវឌ្ឍន៍ជនបទ" ដែលជាជំនួយឥតសំណងសម្រាប់អនុកម្មវិធី (SP1) និង ជាជំនួយថវិកា" ដែលទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណ:សម្រាប់ការអភិវឌ្ឍជនបទ គម្រោងដែលនៅសល់គឺទាក់ទងច្រើនទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ជាពិសេសនៅតំបន់បឹងទន្លេសាប ខេត្តបាត់ដំបង និងសៀមរាប។

ក្នុងរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ស្តីពី "វិមជ្ឈការ និងវិសហមជ្ឈការ " (២០១១), អ្នកនិពន្ធបានលើកឡើងនូវបញ្ហាជាច្រើនដែលពាក់ពន្ធ័ទៅនឹងការអនុវត្តគម្រោង។ យោងតាមលទ្ធផលនៃករណីសិក្សាដែលបានពិនិត្យដោយធនាគារអភិវឌ្ឍន៍អាស៊ី(ADB)[5] មានចំនុចមួយចំនួន ដែលសង្ខេបជូនដូចខាងក្រោម:

- គម្រោងនិរន្តរភាពនៃជីវភាពនៅបឹងទន្លេសាប បានផ្តល់ថវិកាជំនួយដល់ឃុំ ចំនួន៣៧ តាមរយ:មូលនិធិជីវភាពសហគមន៍(CLF) ដើម្បីលើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធសង្គម និងជួយបង្កើតសកម្មភាពប្រមូលចំណូល និងការនេសាទសហគមន៍។ ដោយសារឃុំដែលទទួលបានប្រយោជន៍ពីមូលនិធិជីវភាពសហគមន៍(CLF) មានចំនួនកម្រិត បានបង្កអោយមានការកើនឡើងនូវអសមធិមក្នុងការផ្តល់មូលនិធិរវាងឃុំនានា ដែលបញ្ហានេះនាំឲ្យមានការរាំងស្ទះដល់កិច្ចខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុង ការលើកកម្ពស់សមធិម ។ លើសពីនេះទៅទៀត មូលនិធិជីវភាពសហគមន៍( CLF) បានរួមបញ្ចូលការចំណាយយ៉ាងខ្ពស់សម្រាប់អ្នកពិគ្រោះយោបល់ខាងក្រៅតាមរយ:ការផ្តល់ជាវិភាជន៍ប្រាក់ឈ្នួល។
- អប្រសិទ្ធិភាពនៃការអនុវត្តគម្រោងនេះ : ធនាគារអភិវឌ្ឍអាស៊ី(ADB) និងរដ្ឋបាលថ្នាក់ក្រោមជាតិ ( SNA) មានរបៀបនៃការសំរេច ប្រព័ន្ធគណនេយ្យ សវនកម្ម និងវិធានក្នុងការធ្វើរបាយការណ៍ខុសៗគ្នា ដែលនាំ អោយមានការបំពេញការងារត្រួតស៊ីគ្នា ជាពិសេសក្នុងស្ថានការណ៍ដែលធនធានមានកម្រិត។
- វិធីសាស្រ្តអនុវត្តគម្រោងរបស់ម្ចាស់ជំនួយ និងវិធីសាស្រ្តកម្មវិធីស្ថាប័ន: ដោយសកម្មភាពភាគច្រើនរបស់ម្ចាស់ជំនួយអនុវត្តតាមរយ:គម្រោងដែលមានកម្រិតធនធាន និងមាន

[4] Tariq H. Niazi, Deconcentration and Decentralization in Cambodia (ហ្វីលីពីន:ធនាគារអភិវឌ្ឍអាស៊ី,២០១១), ទ.៨៦-៩៤.

[5] Tariq H. Niazi, Deconcentration and Decentralization in Cambodia (ហ្វីលីពីន:ធនាគារអភិវឌ្ឍអាស៊ី, ២០១១), ទ. ៨៥-៨៦,៨៨.

កាលបរិច្ឆេទច្បាស់លាស់ ដែលមានលក្ខណៈផ្ទុយគ្នាទៅនឹងវិធីសាស្រ្តការងាររបស់កម្មវិធីស្ថាប័ន ដែលមានគោលដៅធានានូវនិរន្តភាព និងគណនេយ្យភាពរយៈពេលវែងនៅគ្រប់កម្រិតទាំងអស់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ(SNA)។

- សវនកម្មផ្ទៃក្រៅរបស់ឃុំត្រូវតែពង្រឹងតាមរយៈអាជ្ញាធរសវនកម្មជាតិ ដោយគិតពីលក្ខណៈពិសេសនៃជំនួយរបស់ដៃគូអភិវឌ្ឍន៍។

លើសពីនេះទៅទៀតដៃគូអភិវឌ្ឍន៍ដូចជា មូលនិធិសង្រ្គោះបន្ទាន់របស់អង្គការសហប្រជាជាតិកុមារអន្តរជាតិ(UNICEF) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ(UNDP) អង្គការសហពន្ធ័អាល្លឺម៉ង់ដើម្បីកិច្ចសហប្រតិបត្តិការអន្តរជាតិ(GIZ) និងសហគមន៍អឺរ៉ុប(EU) ក៏បានដើតួរជាអ្នកផ្តល់ប្រឹក្សាសម្រាប់ក្រសួងសំខាន់ៗ រួមមានទាំង លើការងារអប់រំ សុខាភិបាលនិងផែនការប៉ុន្តែមានការលំបាកក្នុងការសម្របសម្រួលលើការងារកិច្ចសហប្រតិបត្តិការដៃគូអភិវឌ្ឍន៍ទាំងនេះ ទាក់ទងនឹងការគាំទ្រការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

## IV. **សេចក្តីសន្និដ្ឋាន**

យើងឃើញថា នៅមានភាពស្មុគស្មាញចម្បងៗខ្លាំងក្នុងការអនុវត្ត ទោះបីជាមានការរីកចម្រើនគួរឲ្យកត់សម្គាល់ទាក់ទងនឹងការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងរយៈពេលប៉ុន្មានទសវត្សរ៍នេះក៏ដោយ ។ កត្តាដ៏សំខាន់ពីរដែលត្រូវតែដោះស្រាយ ដើម្បីធានាការរីកចម្រើននៃកំណែទម្រង់រួមមានៈ កត្តាទីមួយត្រូវមានការបញ្ជាក់ឲ្យបានច្បាស់លាស់ពីតួនាទីភារកិច្ចរបស់រដ្ឋបាល ថ្នាក់ក្រោមជាតិ និងបញ្ចប់នូវភាពមិនច្បាស់លាស់នេះ ។ កត្តាទីពីរ ក្របខណ្ឌគតិយុត្តិក្នុងការផ្តល់ហិរញ្ញប្បទាន និងការកសាងសមត្ថភាព ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុ និងគណនេយ្យភាពក៏ត្រូវតែបញ្ជាក់ឲ្យច្បាស់លាស់ និងត្រូវបញ្ចប់ដែរ (អនុកម្មវិធីទី៤, ផែនការណ៍អនុវត្តរយៈពេល ៣ឆ្នាំ, ២០១១) ។ ទិដ្ឋភាពដ៏សំខាន់នៃកំណែទម្រង់ទាំងពីរនេះគឺ ជាកត្តាដ៏សំខាន់ក្នុងការធានាជោគជ័យក្នុងការអភិវឌ្ឍ និងអនុវត្ត កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការក្នុងដំណើរការឆ្ពោះទៅមុខ។ បន្ថែមពីនេះទៅទៀតនៅពេលដែលដៃគូអភិវឌ្ឍន៍បាននាំមកនូវការគាំទ្រជាច្រើន ទាំងលើ បច្ចេកទេសនិងហិរញ្ញវត្ថុ ដើម្បីជំរុញការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា បញ្ហា មួយចំនួនត្រូវបានលើកឡើង ដូចដែលបានរៀបរាប់សង្ខេបខាងលើរួមមានទាំងវិធីសាស្រ្ត ការអនុវត្តគម្រោងធៀបនឹងវិធីសាស្រ្តកម្មវិធីជាតិ ដែលមានលក្ខណៈទូលំទូលាយ។

# ឯកសារយោង


Draft Law on Financial Regime and Property Management for Sub-National Administrations, last modified 2012, http://www.cambodianbudget.org/userfiles/Law_Sub-National_Finance_2008_EN.pdf.

Kimchoeun Pak and David Craig, Accountability and Public Expenditure Management in Decentralized Cambodia (Cambodia: CDRI Working Paper 38, 2008).

Ministry of Interior (Cambodia, Situation Analysis of Provincial/Municipal and District/Khan Administration in Cambodia, 2008).

National Assembly (Cambodia, Law on Administration of Communes, 2001).

National Assembly (Cambodia, Law on Taxation, 1997).

National Committee to Support the Commune/Sangkats( Cambodia, Sub-Decree on the Establishment of the Communes/Sangkats Fund, 2002).

NCDD Annual Work Plan (Cambodia, IP3 Extension 2013 of NP-SNDD: 2014 NCDD Annual Work Plan and Budget, 2014).

NCDD Annual Work Plan (Cambodia, IP3: 2013 NCDD Annual Work Plan and Budget, 2013).

Olajumoke Ayandele, Nary Ung and Mathew Tschabold, Assessment of Design Options for the Sub-National Investment Facility (SNIF) in Cambodia ( New York: New York University, Robert F. Wagner Graduate School of Public Service, 2013).

Preah Reach Kram( Cambodia, Law on Audit, 2000).

Royal Government of Cambodia ( Cambodia, National Strategic Development Plan Update 2009-2013, 2009).

Royal Government of Cambodia (Cambodia, Sub-Decree on Decentralization of Powers, Roles and Duties to Commune/Sangkat Councils, 2002).

Royal Kram (Cambodia, Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans, 2008).

Seiha Heng, Sedara Kim and Sokbunthoeun So, Decentralized Governance in Hybrid Policy: Localization of Decentralization and Deconcentration(D&D) Reform in Cambodia (Cambodia: CDRI, 2011).

Tariq H. Niazi, Deconcentration and Decentralization Reforms in Cambodia: Recommendations for an Institutional Framework (Philippines: Asian Development Bank, 2011).

Tariq H. Niazi, Deconcentration and Decentralization Reforms in Cambodia: Recommendations for an Institutional Framework (Philippines: Asian Development Bank, 2011), 77-94.

UNDP(Cambodia: Amended Law on Election of Commune Council, 2006).

Vuthy Horng and David Craig, Accountability and Planning in Decentralized Cambodia (Cambodia: CDRI Working Paper 39, 2008).

World Bank Project Program( Cambodia, Cambodia’s Seila Program: A Decentralized Approach to Rural Development and PovertyReduction, 2004), 1.

# ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១**:ផែនការណ៍ការងារ និងថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំ២០១៤

## The 2014 AWPB budget

### PLANNED EXPENDITURES

**2014 AWPB planned expenditures, financed through the basket fund, are budgeted at $13,586,629.** This is an increase of 28% over 2013. Including the IP3 extension and over the program's four years of implementation, planned expenditures reached $59.21 Million as opposed to a figure of $68.84 Million, as found in the IP3 document (i.e. 14% less than expected). Though operating at a somewhat reduced level and over a longer period of time, resources are considered adequate to produce most of the outputs identified in the IP3.




*ប្រភព: ផែនការណ៍អភិវឌ្ឍរយៈពេល៣ឆ្នាំបន្ត ក្នុងឆ្នាំ២០១៤ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ, ផែនការណ៍ការងារ និងថវិកាប្រចាំឆ្នាំ ២០១៤*

**ឧបសម្ព័ន្ធទី២** :ការចំណាយរបស់អនុ-កម្មវិធីទី១-៤

## Table 1: Overview of Planned 2014 Expenditures

| SP | A. Basket | % Basket | B. Earmarked | C. Fiscal Transfers | Total (A+B+C) | % Total |
|---|---|---|---|---|---|---|
| Sub-Program 1 | $4,835,299 | 35.59% | $17,862,525 | $0 | **$22,697,824** | 8.22% |
| Sub-Program 2 | $575,494 | 4.24% | $4,740,820 | $0 | **$5,316,314** | 1.93% |
| Sub-Program 3 | $356,820 | 2.63% | $0 | $0 | **$356,820** | 0.13% |
| Sub-Program 4 | $175,357 | 1.29% | $5,004,044 | $233,863,704 | **$239,043,105** | 86.59% |
| – Reform Activities | $175,357 | | $1,004,044 | $0 | **$1,179,401** | 0.43% |
| – Fiscal Transfers | $0 | | $4,000,000 | $233,863,704 | **$237,863,704** | 86.16% |
| Sub-Program 5 | $45,490 | 0.33% | $139,000 | $0 | **$184,490** | 0.07% |
| Sub-Program 6 | $120,520 | 0.89% | $389,682 | $0 | **$510,202** | 0.18% |
| SNAs (PC/DMK expenditures) | $7,477,649 | 55.04% | $491,328 | $0 | **$7,968,978** | 2.89% |
| **Total** | **$13,586,629** | **100.00%** | **$28,627,399** | **$233,863,704** | **$276,077,733** | 100.00% |
| % | 4.92% | | 10.37% | 84.71% | 100.00% | |

**NOTE:** ALL CALCULATIONS EXCLUDE IN KIND ACTIVITIES. FISCAL TRANFERS ARE FINANCED BOTH BY THE RGC AND SIDA. SP1 EARMARKED FUNDS INCLUDE A $125,000 CONTRIBUTION BY THE RGC TO NCDDS.

As can be seen above, earmarked expenditures remain 2.1 times as large as discretionary basket funded expenditures. Within the basket, about 55% of all funding goes to SNAs. Data for fiscal transfers is provided in table 2.

## Table 2: Expected Fiscal Transfers 2014

| Fund | Sida | RGC | Total |
|---|---|---|---|
| CS Fund | $0 | $58,584,198 | $58,584,198 |
| DM Fund | $4,000,000 | $17,047,901 | $21,047,901 |
| CP Budget | $0 | $158,231,605 | $158,231,605 |
| Total | **$4,000,000** | **$233,863,704** | **$237,863,704** |

*ប្រភព: ផែនការណ៍អភិវឌ្ឍរយៈពេល៣ឆ្នាំបន្ត ក្នុងឆ្នាំ២០១៤* នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលទ្ធិប្រជាធិបតេយ្យថ្នាក់ក្រោមជាតិ, ផែនការណ៍ការងារ និងថវិកាប្រចាំឆ្នាំ ២០១៤

## **ឧបសម្ព័ន្ធទី៣**: ស្ថានភាពហិរញ្ញវត្ថុ

Figure 3: Status /Progress of 2012 AWPB Outputs




Table 1: Financial Data (excluding fiscal transfers)

| ITEM | BUDGET | EXPENDITURE | % |
|---|---|---|---|
| CENTRAL IMPLEMENTERS | $10,972,723 | $10,289,758 | 93.8% |
| Sub Program 1 (NCDD-S) | $4,320,152 | $4,120,911 | 95.4% |
| Sub Program 2 (MOI) | $1,234,944 | $1,003,170 | 81.2% |
| Sub Program 3 (SSCS) | $156,352 | $55,591 | 35.6% |
| Sub Program 4 (MEF) | $4,838,137 | $4,832,047 | 99.9% |
| Sub Program 5 (MOP) | $183,616 | $89,337 | 48.7% |
| Sub Program 6 (LEAGUE) | $239,523 | $188,702 | 78.8% |
| PROVINCES/CAPITAL | $8,371,334 | $8,041,447 | 96.1% |
| Banteay Meanchey | $336,359 | $313,342 | 93.2% |
| Battambang | $477,134 | $443,799 | 93.0% |
| Kampong Cham | $609,931 | $609,241 | 99.9% |
| Kampong Chhnang | $346,005 | $335,392 | 96.9% |
| Kampong Speu | $381,363 | $359,485 | 94.3% |
| Kampong Thom | $387,119 | $381,490 | 98.5% |
| Kampot | $355,811 | $321,384 | 90.3% |
| Kandal | $457,420 | $453,502 | 99.1% |
| Kep | $162,739 | $145,259 | 89.3% |
| Koh Kong | $277,403 | $263,970 | 95.2% |
| Kratie | $297,811 | $284,794 | 95.6% |
| Mondul Kiri | [illegible] | $261,153 | 98.1% |
| Oddar Meanchey | $260,167 | $253,891 | 97.6% |
| Pailin | $166,931 | $166,582 | 99.8% |
| Phnom Penh | $379,176 | $372,925 | 98.4% |
| Preah Sihanouk | $230,031 | $202,273 | 87.9% |
| Preah Vihear | $310,807 | $306,074 | 98.5% |
| Prey Veng | $504,275 | $498,747 | 98.9% |
| Pursat | $291,600 | $288,577 | 99.0% |
| Ratanak Kiri | $352,450 | $330,890 | 93.9% |
| Siemreap | $448,748 | $399,369 | 89.0% |
| Stung Treng | $285,103 | $275,225 | 96.5% |
| Svay Rieng | $384,619 | $380,100 | 98.8% |
| Takeo | $402,082 | $393,983 | 98.0% |
| Total | $19,344,057 | $18,331,205 | 94.8% |

*ប្រភព: NCDD (ភ្នំពេញ: របាយការណ៍ការអនុវត្តប្រចាំឆ្នាំនៃផែនការណ៍អនុវត្តរយៈពេល៣ឆ្នាំ ចាប់ពីខែ មករា ដល់ធ្នូ ឆ្នាំ ២០១២, ២០១៣), ទ.២១*

**ឧបសម្ព័ន្ធទី៤**: ប្រភពមូលនិធិ

Table 27: Sources of funds

| Source/Balance | Amount | % budget | % balance |
|---|---|---|---|
| 1. Total available funds (budget) | $19,344,057 | 100.00% | |
| 1.1. Sida | $17,518,070 | 90.56% | |
| 1.2. UNICEF | $1,690,717 | 8.74% | |
| 1.3. UN Women | $39,888 | 0.21% | |
| 1.4. ADB | $64,140 | 0.33% | |
| 1.5. WB-OWSO | $31,243 | 0.16% | |
| 1.6. Other income (include c/f $4,683.10) | $4,784 | 0.02% | |
| 2. Actual Expenditure | $18,331,206 | | |
| 3. Balance: Estimated Carry Over to 2013 (item 1 - item 2) | $1,012,851 | | 100.00% |
| 3.1. SIDA | $658,721 | | 65.04% |
| 3.2. UNICEF | $332,154 | | 32.79% |
| 3.3. UN Women | $21,977 | | 2.17% |
| 3.4. ADB | $0 | | 0.00% |
| 3.5. WB-OWSO | $0 | | 0.00% |
| 3.6. Other income | $4,784 | | 0.47% |

*ប្រភព: NCDD (ភ្នំពេញ: របាយការណ៍ការអនុវត្តប្រចាំឆ្នាំនៃផែនការណ៍អនុវត្តរយៈពេល៣ឆ្នាំ ចាប់ពីខែ មករា ដល់ធ្នូ ឆ្នាំ ២០១២, ២០១៣), ទ.៣៤១*

## **ឧបសម្ព័ន្ធទី៥**: ផែនការណ៍ការងារ និងថវិកាប្រចាំឆ្នាំសម្រាប់ឆ្នាំ ២០១៣

Table 1: The IP3 Basket Fund Budget over Time

| Year | A. IP3 Budget | B. Actual Budget | % (B ÷A) | * Reduction |
|---|---|---|---|---|
| 2011 | $30,163,891 | $20,197,852 | 67% | |
| 2012 | $21,639,356 | $14,797,116 | 68% | 27% |
| 2013 | $17,040,191 | $10,625,000 | 62% | 29% |
| Total | $68,843,438 | $45,619,968 | 66% | |

* Reduction from previous year

Table 2: 2013 AWPB Budget Overview

| CATEGORY | RGC | DPs | TOTAL | % |
|---|---|---|---|---|
| 1. IP3 Program Contributions | $65,019,568 | $14,500,000 | $79,519,568 | 35% |
| 1.1. Basket Fund for SPs/SNAs | $125,000 | $10,500,000 | $10,625,000 | 5% |
| 1.2. CS Fund | $50,473,580 | | $50,473,580 | 22% |
| 1.3. DM Fund | $14,420,988 | $4,000,000 | $18,420,988 | 8% |
| 2. Earmarked | $963,262 | $16,820,610 | $17,783,872 | 8% |
| 3. In-Kind | | $4,891,465 | $4,891,465 | 2% |
| 4. PC Budget | $124,001,234 | | $124,001,234 | 55% |
| TOTAL (1+2+3+4) | $189,984,064 | $36,212,075 | $226,196,139 | 100% |

Table 3: DP Source of Funds

| FUNDING SOURCE | PROGRAM | EARMARKED | IN-KIND | TOTAL |
|---|---|---|---|---|
| Sweden/SIDA | $11,500,000 | | | $11,500,000 |
| EU | $3,000,000 | | | $3,000,000 |
| ADB/PPTA | | $403,000 | | $403,000 |
| ADB/DPFSM | | $1,500,000 | | $1,500,000 |
| EU-SPACE | | | $1,500,000 | $1,500,000 |
| Japan/JICA-PILAC | | | $913,409 | $913,409 |
| UNDP | | | $944,056 | $944,056 |
| AusAid | | | $500,000 | $500,000 |
| UNICEF | | $1,125,690 | $1,034,000 | $2,159,690 |
| UNCDF | | $547,450 | | $547,450 |
| UNFPA | | $343,789 | | $343,789 |
| UN/Women | | $54,000 | | $54,000 |
| ADB/TS-PRSDP | | $6,250,691 | | $6,250,691 |
| WB-OWSO | | $1,740,392 | | $1,740,392 |
| WB-LASED | | $4,855,598 | | $4,855,598 |
| TOTAL | $14,500,000 | $16,820,610 | $4,891,465 | $36,212,075 |

*ប្រភព: NCDD (ភ្នំពេញ: របាយការណ៍ការអនុវត្តប្រចាំឆ្នាំនៃផែនការណ៍អនុវត្តរយៈពេល៣ឆ្នាំ ចាប់ពីខែ មករា ដល់ធ្នូ ឆ្នាំ ២០១២, ២០១៣), ទ.៨៧*